**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០០៩/០៤/២០០៨ កបធ.សជណ                    រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០០៨

## ជម្រាបមក

## លោក ចិន សុផល

**កម្មវត្ថុ** : រឿងទាក់ទងនឹងបណ្តឹងរបស់លោក ចិន សុផល តំណាងឱ្យលោក ម៉ក់ ង៉ាន់ ប្តឹងទាមទារសុំឱ្យផ្តន្ទាទោសឈ្មោះ ឡុញ ឃន មេឃុំព្រៃកខ្សាច់ ឈ្មោះ ផន ភារ៉ា នាយរងនគរបាលប៉ុស្តិ៍ ឈ្មោះ យ៉ង់ សេងងួន មេភូមិព្រៃកខ្សាច់ និង ឈ្មោះ ម៉ា កូនមេភូមិចាស់ព្រៃកខ្សាច់ និង បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំបោះឆ្នោត ចុះហត្ថលេខាដោយ ឯកឧត្តម ទេព នីថា លេខ ៩២២/០៨ គ.ជ.ប ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨

**យោង** : បណ្តឹងគ្មានលេខ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០០៨ របស់លោក ចិន សុផល តំណាងឱ្យលោក ម៉ក់ ង៉ាន់ ដែលមានតួនាទីជាតំណាងគណបក្ស សម រង្ស៊ី ឃុំព្រៃកខ្សាច់ ( ខេត្តកោះកុង )

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបមក លោក ចិន សុផល ជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១២ ខែ សីហា ឆ្នាំ២០០៨ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលើបណ្តឹងរបស់លោករួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកបណ្តឹងនេះមកពិភាក្សា និង សម្រេចបានឡើយ ពីព្រោះបណ្តឹងរបស់លោកមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ២៥ថ្មី មាត្រា ២៦ និងមាត្រា ២៧ថ្មី នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និង មាត្រា ៧៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នោះទេ ។

សូមលោកទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**